## ៣. ការរៀបចំជ្រុងថ្នាក់

### ៣.១. ជ្រុងវិទ្យាសាស្ត្រ







ជ្រុងវិទ្យាសាស្ត្រ គឺជាជ្រុងដែលធ្វើឱ្យកុមារស្វែងយល់អំពីបទពិសោធប្រចាំថ្ងៃ និងធ្វើអន្តរកម្មជាមួយគ្រប់ទិដ្ឋភាពទាំងអស់នៃបរិស្ថានរបស់ពួកគេ ដូចជាសាលារៀន ផ្ទះ គ្រួសារ និងព្រឹត្តិការណ៍ផ្សេងៗក្នុងសង្គម។ កុមារចង់ដឹងពីបម្រែបម្រួលនៃបាតុភូតធម្មជាតិក្នុងបរិស្ថានសិក្សាមាន ភាវៈមានជីវិត និងគ្មានជីវិតតាមការចាប់អារម្មណ៍របស់ពួកគេ ដូច្នេះគ្រូមត្តេយ្យសិក្សាដើរតួសំខាន់ជួយសម្រួលដល់ដំណើរការរៀបចំសកម្មភាពដើម្បីឱ្យសម្រេចបាននូវអ្វីដែលកុមារបានពេញចិត្តចង់ដឹងចង់ឃើញរំភើប និងទទួលបានចំណេះដឹង បំណិនកាន់តែច្រើនប្រកបដោយលក្ខណៈវិទ្យាសាស្ត្រ និងមានប្រសិទ្ធភាព។

#### ៣.១.១. លទ្ធផលរំពឹងទុកលើការអភិវឌ្ឍរបស់កុមារ

| | |
|---|---|
| វិជ្ជាសម្បទា | - ប្រាប់បានពីការលូតលាស់ និងលក្ខខណ្ឌរស់នៅរបស់មនុស្ស សត្វ និងរុក្ខជាតិ<br>- ប្រាប់បានពីបម្រែបម្រួលអាកាសធាតុ វត្ថុ និងបាតុភូតធម្មជាតិដែលនៅជុំវិញកុមារ<br>- ប្រាប់បានពីវប្បធម៌(ប្រាសាទ) សង្គម(ពិធីបុណ្យផ្សេងៗ) វិទ្យាសាស្ត្រងាយៗ។ |
| បំណិនសម្បទា | - កំណត់បានពីលូតលាស់ និងលក្ខខណ្ឌរស់នៅរបស់មនុស្ស សត្វ និងរុក្ខជាតិ<br>- កំណត់បានពីបម្រែបម្រួលអាកាសធាតុ វត្ថុ និងបាតុភូតធម្មជាតិដែលនៅជុំវិញកុមារ<br>- កំណត់បានពីវប្បធម៌ ពិធីបុណ្យប្រពៃណីផ្សេងៗ និងពិធីបុណ្យសាសនាក្នុងសង្គមរស់នៅ។ |
| ចរិយាសម្បទា | - ស្រឡាញ់ចូលចិត្ត ថែរក្សា និងការពារជីវិតមនុស្ស សត្វ និងរុក្ខជាតិ<br>- រីករាយចូលរួមធ្វើសកម្មភាពពិសោធដោយមានបម្រុងប្រយ័ត្ន និងមានសុខសុវត្ថិភាព<br>- យកចិត្តទុកដាក់ផ្សាភ្ជាប់ខ្លួននឹងការប្រែប្រួលអាកាសធាតុ<br>- ចាប់អារម្មណ៍ទៅលើធម្មជាតិ និងវិទ្យាសាស្ត្រកាន់តែខ្លាំង។ |

#### ៣.១.២. ការរៀបចំ

**ក. ការរៀបចំធ្នើរ ឬតុ៖**

- ជ្រើសរើសធ្នើរ ឬតុសមស្របនឹងកម្ពស់កុមារ ធានាសុវត្ថិភាព ងាយស្រួលប្ដូរទីតាំងនៅថ្នាក់រៀន។
- ធ្នើរ ឬតុត្រូវដាក់នៅក្បែរមាត់បង្អួច ឬទ្វារដែលមានពន្លឺ និងខ្យល់គ្រប់គ្រាន់។
- រៀបចំទូ ឬធ្នើរមួយដែលអាចដាក់តាំងសម្ភារៈសម្រាប់ពិសោធដូចជាគ្រាប់ពូជ គ្រាប់ធញ្ញជាតិ កែវចិញ្ចឹមត្រីជាដើម។

**ខ. ការផ្លាស់ប្ដូរសម្ភារៈតាមសកម្មភាព៖**

- តាំងវត្ថុពិត ឬវត្ថុដែលទាក់ទងនឹងវិទ្យាសាស្ត្រទៅតាមប្រធានបទសកម្មភាពថ្នាក់រៀន។
- គ្រូជាអ្នកគិតច្នៃប្រឌិតរៀបចំដាក់តាំង ឱ្យកុមារអនុវត្ត បង្កើនការយល់ដឹង ហើយកុមារស្រាវជ្រាវ បន្ថែមលើប្រធានបទដែលកំពុងរៀន។
- គ្រូសង្កេតមើលសកម្មភាពកុមារ តើពួកគេចាប់អារម្មណ៍លើអ្វីដែលកំពុងតាំងដែរឬទេ និងគួររៀបចំរយៈពេលយូរប៉ុណ្ណា។
- ភាវៈមានជីវិតដូចជាកូនរុក្ខជាតិ ត្រី ក្ដាម ខ្យង ... មិនអាចតាំងយូរបើសិនគ្មានការថែទាំបានល្អ។
- វត្ថុផ្សេងៗអាចតាំងបានយូរគឺឧបករណ៍វាស់កំដៅ ចំណីអាហារ គ្រឿងអលង្ការ និងល័ក្ខជ្រលក់ ពណ៌ទឹកពណ៌(គូល័រទឹក).....។

**គ.ការរៀបចំប្រកបដោយភាពទាក់ទាញ៖**

- រៀបចំយ៉ាងណាឱ្យកុមារចាប់អារម្មណ៍ទៅលើជ្រុងនេះ។
- រៀបចំធ្វើឱ្យកុមារយល់ច្បាស់ពីការលូតលាស់របស់រុក្ខជាតិ សត្វ កត់ត្រាពីការលូតលាស់ និងធ្វើការសង្កេតបន្តទៀត កុមារនឹងភ្លេចបើសិនជាលោកគ្រូ អ្នកគ្រូមិនធ្វើការរំឭកឡើងវិញ។
- រៀបចំវត្ថុដាក់តាំងឱ្យមានសណ្ដាប់ធ្នាប់របៀបរៀបរយ។

**ឃ. ការតាំងសៀវភៅ ឬផ្ទាំងរូបភាពស្របនឹងប្រធានបទ៖**

- សៀវភៅរូបភាពវិទ្យាសាស្ត្រ ឬសៀវភៅរឿងទាក់ទងវិទ្យាសាស្ត្រ។
- ផ្ទាំងរូបភាពបង្ហាញពីប្រធានបទមេរៀនក្នុងកម្មវិធីសិក្សាដែលត្រូវរៀនក្នុងថ្នាក់។
- រៀបចំសៀវភៅរូបភាពវិទ្យាសាស្ត្រ ឬសៀវភៅរឿងទាក់ទងវិទ្យាសាស្ត្របង្ហាញរូប។

## ឧទាហរណ៍

### ពិសោធន៍ឥន្ទធនូ





ថ្ងៃមួយគ្រូបានរៀបចំព្រឹត្តិការណ៍ផ្សាភ្ជាប់នឹង«អាកាសធាតុ» នៅក្នុងជ្រុងវិទ្យាសាស្ត្រ។ ក្នុងពេលនោះគ្រូបាននិទានរឿងទាក់ទងនឹងអាកាសធាតុ និងសកម្មភាពច្នៃប្រឌិត។ ករណីនេះបានធ្វើឱ្យកុមារចង់ដឹងបន្ថែមទៀតអំពីអាកាសធាតុ។ ជំហានបន្ទាប់គ្រូរៀបចំសកម្មភាពដែលកុមារបានឃើញ និងទទួលបាននូវអ្វីក្នុងសៀវភៅរូបភាពមកភ្ជាប់វាទៅនឹងជីវិតប្រចាំថ្ងៃ ដូចជាព្រះអាទិត្យ ភ្លៀង ខ្យល់ ឥន្ទធនូ ផ្កាយ ឬបាតុភូតធម្មជាតិផ្សេងៗកើតឡើងនៅលើមេឃរាល់ថ្ងៃ ដែលកុមារបានស្គាល់ច្បាស់។ ការពិសោធសាមញ្ញក៏ជួយកុមារឱ្យរៀនបន្ថែមអំពីគ្នាទៅវិញទៅមក ហើយបង្វែរចំណេះដឹងរបស់ពួកគេឈានទៅបំណិនផ្សេងៗ។ ប្រសិនបើគ្រូអាចរៀបចំសកម្មភាពបន្តនៅជ្រុងវិទ្យាសាស្ត្រនោះ កុមារនឹងកាន់តែចង់ដឹងអំពីអ្វីៗ ផ្សេងទៀតនៅជុំវិញខ្លួនដោយភាពរីករាយ។

| មុខវិជ្ជា(១) | - សិក្សាសង្គម (សកម្មភាពកសាង ការបង្កើតរូបភាពឥន្ទធនូ) |
|---|---|
| វត្ថុបំណង | វិជ្ជាសម្បទា៖<br>- ប្រាប់បានពីរបៀបបិទក្រដាសពណ៌តូចៗបង្កើតជារូបឥន្ទធនូ<br>- ប្រាប់បានពីលក្ខណៈ រូបរាង ពណ៌របស់ឥន្ទធនូ ។<br>បំណិនសម្បទា៖<br>- ប្រើការលាបលើក្រដាសពណ៌តូចៗបិទតាមពណ៌របស់ឥន្ទធនូ<br>- បង្ហាញបានរបៀបបង្កើតរូបឥន្ទធនូ។<br>ចរិយាសម្បទា៖<br>- សហការគ្នាបង្កើតរូបភាពឥន្ទធនូ<br>- ឈ្លាសវៃ រហ័សរហួន ប៉ិនប្រសប់បិទការលើក្រដាសពណ៌តូចៗបង្កើតជារូបឥន្ទធនូមានសោភ័ណ។ |
| ថ្នាក់/អាយុ | - កម្រិតមធ្យម កុមារអាយុ៤ឆ្នាំ |
| រយៈពេល | - ៣០នាទី(១ម៉ោងសិក្សា) |



| សម្ភារៈ | ១. ការនិទានរឿង<br>- សៀវភៅរូបភាពទាក់ទងនឹងអាកាសធាតុ ឬឥន្ទធនូ<br>២. បង្កើតរូបឥន្ទធនូ<br>- ក្រដាសធំ ក្រដាសពណ៌(ហែកជាបំណែកតូចៗ) ចានតូចៗ ទឹក កាវបិទអេធីអឹម កន្សែងសើមសម្រាប់សម្អាតដៃ។ |
|---|---|
| របៀបលេង | - ចែកកុមារជាក្រុមតូចៗទៅតាមចំនួនកុមារ<br>- រៀបចំសម្ភារៈទៅតាមក្រុមនីមួយៗ<br>- គ្រូបានត្រៀមទុកជាមុនផ្ទាំងរូបភាពដែលឱ្យកុមារបិទតាមពណ៌ជាគម្រូផ្ទាំងធំបិទចន្លោះៗទុកឱ្យកុមារបំពេញ ហើយកាត់ផ្ទាំងធំនោះជាចំណែកតាមក្រុមកុមារ<br>- គ្រូបានហែកក្រដាសចំនួន៥ពណ៌តូចៗ រួចជាស្រេច។<br>- កុមារជ្រើសរើសក្រដាសពណ៌តូចៗដែលខ្លួនស្រឡាញ់បិទទៅលើផ្ទាំងដែលគ្រូចែកឱ្យតាមក្រុម<br>- ពេលចប់គ្រូប្រមូលក្រដាសផ្ទាំងធំតាមក្រុមមកបិទភ្ជាប់គ្នាបង្កើតជារូបឥន្ទធនូធំដាក់តាំងនៅជ្រុងសិល្បៈ។ |

| មុខវិជ្ជា(២) | វិទ្យាសាស្ត្រ (ពិសោធន៍ឥន្ទធនូ) |
|---|---|
| វត្ថុបំណង | វិជ្ជាសម្បទា៖<br>- ប្រាប់បានពីលក្ខណៈពណ៌ រូបរាង និងពេលវេលាដែលកើតមានបាតុភូតឥន្ទធនូ។<br>បំណិនសម្បទា៖<br>- ពណ៌នាអំពីពណ៌របស់ឥន្ទធនូ។<br>ចរិយាសម្បទា៖<br>- យកចិត្តទុកដាក់ទៅលើបម្រែបម្រួលអាកាសធាតុ<br>- រីករាយនឹងការពិសោធឥន្ទធនូ។ |
| ថ្នាក់/អាយុ | - កម្រិតមធ្យម កុមារអាយុ៤ឆ្នាំ |
| រយៈពេល | - ៣០នាទី |
| សម្ភារៈ | - សៀវភៅរូបភាពទាក់ទងនឹងអាកាសធាតុ ឬឥន្ទធនូ(បង្ហាញតែរូបភាព)។<br>- ដបទឹកថ្លា ឬថាសឌីសចាស់ៗ ពិល ប្រអប់ក្រដាស។ |
| របៀបលេង | - ដាក់ដបទឹកថ្លា ឬថាសឌីសចាស់ៗ នៅក្នុងប្រអប់មួយ ហើយបញ្ចាំងពន្លឺពិលឱ្យមានពន្លឺផ្លេកប៉ះនឹងដបទឹកថ្លា ឬថាសឌីសចាស់ៗ<br>- ពន្លឺផ្លេកចាំងផ្លាតទៅប៉ះនឹងផ្ទៃប្រអប់នោះ យើងអាចឃើញរូបឥន្ទធនូនៅផ្ទៃប្រអប់នោះយ៉ាងច្បាស់។ |
| សម្គាល់៖ | - សូមនាំកុមារទៅមើលផ្ទាល់ប្រសិនបើមានបាតុភូតពិតប្រាកដ<br>- មុនធ្វើសកម្មភាពជាមួយកុមារគ្រូគួរធ្វើពិសោធជាមុន<br>- គ្រូអាចរកពិសោធផ្សេងៗទៀតតាមការច្នៃប្រឌិត។ |

## ១. ការរៀបចំបរិស្ថាន និងការចូលរួមរបស់គ្រូ

### បរិស្ថាន



- រៀបចំទីធ្លាធំទូលាយដែលកុមារអាចមើលឃើញអ្នកគ្រូនិទានរឿង និងបិទក្រដាសតូចៗទៅលើក្រដាសផ្ទាំងធំបានជុំគ្នា (ឧទាហរណ៍អង្គុយជារង្វង់ ឬពាក់កណ្ដាលរង្វង់អំឡុងពេលនិទានរឿង បង្កើតឥន្ទធនូនៅលើតុ ឬផ្ទាល់កម្រាលការ៉ូ)។
- បន្ទាប់ពីនិទានរឿង ចែកកុមារជា២ ឬ៣ក្រុម តាមចំនួនកុមារតិច ឬច្រើនសម្រាប់សកម្មភាពបិទឥន្ទធនូ។

### ការចូលរួមរបស់គ្រូ



**១. ការនិទានរឿង**
- គ្រូចាប់ផ្ដើមនិទានរឿង។



**២. ការបិទរូបឥន្ទធនូ**
- គ្រូគូររូបរាងឥន្ទធនូនៅលើក្រដាសធំជាមុន។
- ពន្យល់កុមារពីរបៀបប្រើសម្ភារៈបិទឥន្ទធនូ។
- គ្រូចូលរួមជាមួយកុមារ ហើយជជែកជាមួយពួកគេ។
- លើកទឹកចិត្តឱ្យកុមាររៀបចំសម្ភារៈទាំងអស់នៅពេលចប់សកម្មភាព។



**៣. ពិសោធន៍ឥន្ទធនូ**
- ណែនាំកុមារកុំឱ្យមើលពន្លឺពិលផ្ទាល់ភ្នែក។
- ឆ្លើយតបនឹងការភ្ញាក់ផ្អើលពេលកុមាររកឃើញឥន្ទធនូនៅក្នុងប្រអប់ដែលចាំងផ្លាតពីស៊ីឌី ឬដប់ទឹកថ្លា។

## ២. សកម្មភាពឆ្លើយតបរបស់កុមារ និងលទ្ធផល



ពិតជាសប្បាយណាស់បានធ្វើការរួមគ្នាអីចឹង!

- តាមរយៈការនិទានរឿងរបស់គ្រូ និងសកម្មភាពបិទរូបឥន្ទធនូពីក្រដាសពណ៌តូចៗ កុមារចាប់អារម្មណ៍នឹងឥន្ទធនូជាខ្លាំង។ កុមារបានជ្រើសរើសពណ៌របស់ឥន្ទធនូដោយខ្លួនឯង និងសហការគ្នាបិតក្រដាសចម្រុះពណ៌។ កុមារឈ្មោះដារ៉ា និងមិត្តភក្តិបានប្រាប់គ្រូថាចង់ឃើញពណ៌ពិតនៃឥន្ទធនូ។
- គ្រូបានប្រាប់កុមារវិញថា«ថ្ងៃស្អែកអ្នកគ្រូនឹងបង្ហាញឥន្ទធនូដល់កូន»។ នៅថ្ងៃបន្ទាប់អ្នកគ្រូបាននាំកុមារទៅមើលជ្រុងវិទ្យាសាស្ត្រ ឱ្យកុមារពិសោធបញ្ចាំងពិលលើថាសឌីស នៅក្នុងប្រអប់។ «មើល! មានឥន្ទធនូនៅលើប្រអប់នេះ។ ពិតជាស្រស់ស្អាតណាស់!» កុមារមានការភ្ញាក់ផ្អើលដែលមានឥន្ទធនូតូចបានបង្ហាញខ្លួននៅប្រអប់ចំពោះមុខពួកគេ។
- ចាប់ពីពេលនោះមក កុមារចាប់ផ្ដើមចាប់អារម្មណ៍លើឥន្ទធនូកាន់តែខ្លាំង។ ធីតាបាននិយាយថា«ពេលខ្ញុំជួយឪពុកខ្ញុំលាងឡាននៅផ្ទះ ខ្ញុំបានបាញ់ទឹកទៅលើ នៅពេលនោះ ខ្ញុំក៏មើលឃើញឥន្ទធនូដែរ»។ ក្នុងថ្នាក់រៀន កុមារបានចាប់ផ្ដើមប្រាប់គ្នាថា លើអាវមិត្តភក្តិរបស់កុមារម្នាក់ និងនៅក្នុងថ្នាក់រៀនក៏មានរូបឥន្ទធនូដែរ។ គ្រូបានដឹងជាថ្មីម្ដងទៀតថាកុមារអាចរៀនយ៉ាងសកម្មតាមរយៈបទពិសោធនេះ។



កុមារបញ្ចាំងពិលលើថាសឌីស មើលឥន្ទធនូ



មានឥន្ទធនូតូចនៅក្នុងថ្នាក់រៀន យើងដែរ

## គន្លឹះបន្ថែម

ការរៀបចំជ្រុងវិទ្យាសាស្ត្រតាមប្រភេទរឿងនិទាន ឬសកម្មភាព

ក. រឿង«បំណងគ្រាប់បាយ»៖ សាច់រឿងនេះចង់និយាយអំពីបំណងរបស់គ្រាប់បាយដែលចង់ចិញ្ចឹមមនុស្សលោក តែមនុស្សលោកបែរជាខ្ជីខ្ជាហូបចុកមិនសន្សំសំចៃទៅវិញ។ អត្ថន័យរឿងនេះគឺចង់ឱ្យមនុស្សស្រឡាញ់អាហារ ហើយហូបចុកត្រូវចេះសន្សំសំចៃ។ ចេញពីរឿងនេះ យើងរៀបចំជ្រុងវិទ្យាសាស្ត្រដូចខាងក្រោម ជាឧទាហរណ៍។








តាំងសៀវភៅរឿង «បំណងគ្រាប់បាយ»

ដាក់តាំងគ្រាប់ស្រូវ

ដាក់តាំងដើមស្រូវ



ដាក់តាំងសំណាបក្នុងកែវមានទឹក ដើម្បីបង្ហាញពីមជ្ឈដ្ឋានដែលវាលូតលាស់



ដាក់តាំងគ្រាប់អង្ករ

ខ. រឿង«ឱឱរៀនមើលម៉ោង»៖ សាច់រឿងនេះចង់បង្រៀនពីរបៀបមើលម៉ោងនៅលើនាឡិកា។ បន្ទាប់ពីនិទានរឿងនេះចប់ហើយ យើងអាចរៀបចំជ្រុងវិទ្យាសាស្ត្រដូចគំរូខាងក្រោម។



នាឡិកាផលិតពីក្រដាស

សៀវភៅរឿង

នាឡិកាពិត

គ. រឿង«យើងយោងបងខ្លា»៖ ខ្លាចង់ឆ្លងជ្រលងភ្នំមកលេងជាមួយសត្វដទៃទៀតនៅម្ខាងទៀត។ ដើម្បីឆ្លងបាន សត្វដទៃទៀតធ្វើជងយោង។ ដូច្នេះ យើងអាចរៀបនៅជ្រុងនេះដូចខាងក្រោម។



សៀវភៅរឿង

ដាក់តាំងតុក្កតាខ្លះដូចក្នុងសាច់រឿង

ផលិតជងយោងពីសម្ភារៈផ្សេងៗ ប្រើប្រាស់គំនិតច្នៃប្រឌិតផ្ទាល់ខ្លួន

## គន្លឹះបន្ថែម

ឃ. រឿង«កុលាបពីរទង»៖ សាច់រឿងចង់ប្រៀបធៀបពីភាពខុសគ្នារវាងកុលាបពីរទង មួយជាផ្កា កុលាបពិត និងមួយទៀតជាផ្កាកុលាបសិប្បនិម្មិត។ អត្ថន័យអប់រំក្នុងរឿងនេះគឺចង់ឱ្យមនុស្សបេះ ស្រឡាញ់បរិស្ថាន ស្រឡាញ់ធម្មជាតិ។ ចេញពីរឿងនេះ យើងអាចរៀបចំជ្រុងវិទ្យាសាស្ត្រដូចខាង ក្រោម។






ផ្កាពិត បើគ្មានផ្កាកុលាប អាចដាក់តាំងផ្កាផ្សេងជំនួសបាន




សៀវភៅរឿង



ផ្កាសិប្បនិម្មិត បើគ្មានផ្កាកុលាប អាចដាក់តាំងផ្កាផ្សេងជំនួសបាន

ង. មេរៀនទាក់ទងនឹងពណ៌៖ បន្ទាប់ពីគ្រូបង្រៀនមេរៀនអំពីពណ៌ដល់កុមារ យើងអាចរៀបចំជ្រុងវិទ្យាសាស្ត្រដូចខាងក្រោម។




ទឹកសម្រាប់លាយពណ៌ | ចានលាយពណ៌ និងជក់ | សៀវភៅ អំពី «ពណ៌» | ថ្នាំពណ៌ ឬគូល័រ




អនុញ្ញាតឱ្យកុមារបានអនុវត្តន៍លាយពណ៌

## ៣.២. ជ្រុងអនាម័យ





ជ្រុងអនាម័យរៀបចំឡើងដើម្បីឱ្យកុមារបានប្រើប្រាស់ដូចជា អនាម័យខ្លួនប្រាណ អវៈយវៈ ចៀសវាងពីជំងឺផ្សេងៗ និងបង្កើតទម្លាប់ល្អក្នុងការរស់នៅ។ កុមារផឹកទឹកស្អាត ចេះលាងសម្អាតដៃមុនពេលញ៉ាំចំណីអាហារ និងចេញពីបន្ទប់ទឹក ឬបង្គន់ពេលបត់ជើងរួច ចេះពាក់ម៉ាស់ការពារជាប្រចាំ ចេះរៀបចំសម្លៀកបំពាក់ មុខ មាត់ និងផ្ទះកញ្ចក់សិតសក់បានសមរម្យ។

### ៣.២.១. លទ្ធផលរំពឹងទុកលើការអភិវឌ្ឍរបស់កុមារ

| | |
|---|---|
| វិជ្ជាសម្បទា | - ប្រាប់បានពីរបៀបលាងសម្អាតដៃមុន ក្រោយពេលបរិភោគចំណីអាហារ និងពេលចេញពីបន្ទប់ទឹក ឬបង្គន់ និងក្រោយពេលក្អក កណ្តាស់<br>- ប្រាប់បានពីរបៀបអនាម័យខ្លួនប្រាណ អវៈយវៈ មុខ មាត់ សក់ក្បាលនិងសម្លៀកបំពាក់ឱ្យស្អាតជានិច្ច<br>- ប្រាប់បានពីរបៀបពាក់ម៉ាស់ការពារជំងឺឆ្លងផ្សេងៗ។ |
| បំណិនសម្បទា | - ជួយសម្អាតបរិស្ថានដូចជាបន្ទោរបង់ឬខាកស្តោះ ទុកដាក់សំរាមក្នុងធុងសំរាម តាមកន្លែងកំណត់<br>- លាងសម្អាតដៃជាមួយសាប៊ូ អាល់កុលឬជែលមុននិងក្រោយញ៉ាំអាហារ ក្រោយពេលចេញពីបង្គន់ឬប៉ះពាល់របស់កង្វក់និងពេលក្អក កណ្តាស់<br>- ញ៉ាំទឹកស្អាត និងប្រើប្រាស់ម៉ាស់បានត្រឹមត្រូវតាមការណែនាំ។ |
| ចរិយាសម្បទា | - ទម្លាប់រស់នៅស្អាត មានអនាម័យល្អក្នុងការរស់នៅ រៀនសូត្រ ហូបស្អាត ផឹកស្អាត ចេះការការពារខ្លួនពីជំងឺផ្សេងៗ<br>- ស្រឡាញ់បរិស្ថានជុំវិញពោរពេញដោយភាពស្រស់ស្អាតគ្មានសំរាមគ្មានប្លាស្ទីច...។ |



### ៣.២.២. ការរៀបចំ

**ក. សម្ភារៈអនាម័យ៖** រៀបចំឱ្យមានកន្សែងជូតដៃ កញ្ចក់ និងក្រាស់សិតសក់ សាប៊ូ ធុងសំរាមអំបោស តង្កៀបចាប់សំរាម ធុងទឹកចម្រោះ ធុងទឹកសម្រាប់ធ្វើអនាម័យថ្នាក់រៀន ធុងទឹកលាងដៃ ឬកន្លែង សម្រាប់លាងសម្អាតនៅជិតថ្នាក់រៀន តាមលទ្ធភាពរបស់សាលារៀន។

**ខ. ការថែទាំជ្រុង៖**



- រៀបចំឱ្យមានកា ឬកែវផឹកទឹកសម្រាប់កុមារម្នាក់ៗ ឬមានដបទឹកដែលកុមារយកមករៀងខ្លួន និងមានបិទស្លាកសញ្ញាសម្គាល់។
- រៀបចំឱ្យមានកា ឬកែវទឹកសម្រាប់កុមារម្នាក់ៗឬមានដបទឹកដែលកុមារយកមករៀងៗខ្លួន និងមានបិទស្លាកសញ្ញាសម្គាល់ដោយរៀបចំដាក់ក្នុងកញ្ច្រែងមានគម្របដើម្បីការពារមេរោគឆ្លងផ្សេងៗ។
- ត្រូវមានទឹកស្អាត ឬធុងទឹកចម្រោះសម្រាប់កុមារញ៉ាំ។
- រៀបចំកន្លែងលាងសម្អាតដៃខាងក្រៅ ជិតថ្នាក់រៀន ឬធុងលាងសម្អាតដៃ។

**គ. ការថែរក្សាអនាម័យ៖**



- ពន្យល់កុមារពីទម្លាប់អនាម័យជាប្រចាំ។
- ដឹកនាំកុមារផលិតធុងសំរាមពីសំបកប្រអប់ក្រដាស ដូច្នេះកុមារភ្ញាក់រឭកទុកដាក់សំរាមបានត្រឹមត្រូវ។
- បិទតាំងរូបសញ្ញាពីរបៀបលាងសម្អាតដៃ ដើម្បីឱ្យកុមារបន្តលាងដៃដោយរីករាយ។
- រៀបចំល្បែងត្រាប់តាម រូបភាព ឬរូបថតអប់រំកុមារពីអនាម័យមុខ មាត់ ដៃ...។

## ៣.៣. ជ្រុងសិល្បៈ





ជ្រុងសិល្បៈមានមុខងារ២៖ ទីមួយ ជាកន្លែងដាក់តាំងគ្រប់ស្នាដៃរបស់កុមារ ឧបករណ៍ភ្លេងខ្លះៗ និងទីពីរ ជាកន្លែងលេង និងសាកល្បងការងារសិល្បៈដូចជារាំ លេងឧបករណ៍ភ្លេងបុរាណ ឬសម័យ ងាយៗ តុក្កតាជាដើម ដែលទាក់ទងនឹងកុមារមត្តេយ្យ។ ជ្រុងនេះមានសកម្មភាពផ្សេងៗជាច្រើននៅថ្នាក់មត្តេយ្យសិក្សា ដែលកុមារបានចូលរួមអនុវត្តន៍ និងបង្កើតជាលទ្ធផលសិក្សាហៅថាស្នាដៃកុមារ( សិល្បៈ ) ដូចជាបត់រូប គូររូប ហែកបិទតាមស្នាមចុចៗ ពោយកម្ទេចកម្ទីតូចៗលើរូប(អាចម៍រណា កម្ទេចក្រដាស ស្លឹកឈើ...) ដោត ដេរ ត្បាញ កាត់បិទរូប ហែកបិទរូប សូនរូប ផលិតសម្ភារៈនានា យកមកដាក់តាំង។

### ៣.៣.១. លទ្ធផលរំពឹងទុកលើការអភិវឌ្ឍរបស់កុមារ

| | |
|---|---|
| វិជ្ជាសម្បទា | - ប្រាប់បានពីឈ្មោះឧបករណ៍ភ្លេងខ្មែរ ទ្រ ស្គរ ឆាប ឈិង... ចំណងជើងបទចម្រៀង ចង្វាក់រាំ ពណ៌សម្លៀកបំពាក់តាមថ្ងៃ សម្លៀកបំពាក់ប្រពៃណី និងព្រឹត្តិការណ៍សង្គម។<br>- ប្រាប់បានពីឈ្មោះសម្ភារៈនានាដែលផលិតបានដូចជារូបកែវ ក្បាលសត្វ ផ្កា សត្វស្លាប ដង្កូវ កន្ទេល សត្វ និងរូបភាពផ្សេងៗ<br>- ប្រាប់ពីរបៀបបត់ ពោយ ដោត ដេរ ត្បាញ សូនរូប គូរ ផាត់ពណ៌ ហែកបិទ ដែលបានដាក់តាំងស្នាដៃ។ |
| បំណិនសម្បទា | - បង្ហាញពីការប្រើប្រាស់ឧបករណ៍ភ្លេងខ្មែរទ្រស្គរ ឆាប ឈិង ... សម្លៀកបំពាក់ និងសូត្រកំណាព្យ ច្រៀងចម្រៀង ធ្វើកាយវិការ ព្រមទាំងច្រៀងបទនគររាជ ពង្សាវតារខ្មែរបានត្រឹមត្រូវ<br>- បង្កើតបានស្នាដៃតាមរយៈការបត់ក្រដាសបានជារូបផ្សេងៗ សូនរូប ពោយ ដេរ ត្បាញ គូរ ផាត់ពណ៌ ហែក និងកាត់បិទ។ |
| ចរិយាសម្បទា | - ស្រឡាញ់ឧបករណ៍ភ្លេងខ្មែរ សម្លៀកបំពាក់ប្រពៃណី ចង្វាក់រាំ និងចូលចិត្តសូត្រកំណាព្យ ច្រៀងបទនគររាជ ពង្សាវតារខ្មែរ និងចម្រៀងថ្នាក់មត្តេយ្យសិក្សា<br>- មានអារម្មណ៍រំភើបសប្បាយរីករាយពេលឃើញស្នាដៃខ្លួនដែលត្រូវបានដាក់តាំង<br>- មានមោទនភាពចំពោះទេពកោសល្យដែលគេបានធ្វើ និងចង់បង្ហាញស្នាដៃខ្លួនទៅអ្នកដទៃ។ |



### ៣.៣.២. ការរៀបចំ

**ក. ការរៀបចំកន្លែងដាក់សម្ភារៈសិល្បៈ៖**



- ដាក់តុ ធ្នើរ ឬកញ្ច្រែងតាំងឧបករណ៍ភ្លេងខ្មែរទ្រ ស្គរ ឆាប ឈិង និងសម្ភារៈភ្លេងងាយៗដែលកុមារផលិតបាន។
- តាំងស្នាដៃកុមារលើក្រដាសកាតុងរឹង ផ្ទាំងស្មោរ ផ្ទាំងប្លាស្ទិច ឬក្តារខៀនកម្ទី។
- ជ្រើសរើសពណ៌ខៀវ ឬបៃតងចាស់សម្រាប់ធ្វើផ្ទាំងដាក់តាំងស្នាដៃដើម្បីឱ្យកុមារមើលឃើញរូបភាពបានច្បាស់។
- កម្ពស់ផ្ទាំងរូបភាពនៃជ្រុងសិល្បៈគួរឱ្យសមល្មមនឹងកម្ពស់កុមារ។

**ខ. ការដាក់តាំងស្នាដៃកុមារ៖**



- ដាក់តាំងស្នាដៃកុមារឱ្យបានច្រើន និងផ្លាស់ប្តូរញឹកញាប់យ៉ាងតិច២ ឬ៣ដងក្នុងមួយខែ។
- ដាក់តាំងស្នាដៃកុមារប្រមូលពីសកម្មភាពថ្នាក់មត្តេយ្យសិក្សាប្រចាំថ្ងៃដូចជាបត់រូប គូររូប ហែកបិតតាមស្នាមចុច ពោយកម្ទេចផ្សេងៗលើរូប ដេរ ត្បាញ កាត់បិតរូប ផលិតសម្ភារៈនានា។
- ត្រូវដាក់តាំងស្នាដៃកុមារគ្រប់គ្នាដើម្បីជាការលើកទឹកចិត្តដល់កុមារ។
- ដឹកនាំកុមារចូលរួមតុបតែង ឬដាក់តាំងជ្រុងនេះជាការប្រសើរ ហើយការរៀបចំនេះបម្រើដល់ប្រធានបទនៃការសិក្សាធ្វើឱ្យកុមារយល់បានកាន់តែច្បាស់។

**គ. សោភណភាព**



- ការរៀបចំតាំងឧបករណ៍ភ្លេង សម្ភារៈលេងឱ្យមានរបៀបដាក់វត្ថុពីតូចទៅធំតាមលំដាប់លំដោយដើម្បីឱ្យកុមារអាចមើលឃើញសម្ភារៈទាំងនេះបានច្បាស់ងាយស្រួលយកប្រើប្រាស់ និងទុកដាក់ត្រឹមត្រូវ។
- តុបតែងលម្អផ្កាភ្ញីនៅកន្លែងតាំងស្នាដៃកុមារឱ្យមានភាពទាក់ទាញ បង្កើតសោភ័ណភាព ប៉ុន្តែមិនស្មុគស្មាញ។

## ឧទាហរណ៍

### គំនូរសេរី



នៅដើមឆ្នាំសិក្សា គំនូរគឺជាផ្នែកមួយនៃការលេងដ៏ពេញនិយមបំផុតសម្រាប់កុមារ។ គំនូរមិនត្រឹមតែផ្តល់ភាពរីករាយប៉ុណ្ណោះទេប៉ុន្តែវាក៏ជួយកុមារឱ្យបង្កើនជំនាញដូចជាការស្គាល់ពណ៌ ការច្នៃប្រឌិត ការប្រើម្រាមដៃកាន់ជក់ ឬខ្មៅដៃពណ៌បានល្អ និងកម្រិតនៃការផ្តោតអារម្មណ៍របស់កុមារទៅលើរូបភាព។ ដូច្នេះគ្រូបានរៀបចំសកម្មភាពគូរគំនូរសេរី ដើម្បីឱ្យកុមារបានរីករាយជាមួយនឹងសម្ភារៈលាយពណ៌។ កុមារគិត និងចាប់អារម្មណ៍ប្លែកច្រើនជាងមនុស្សធំ ហើយព្យាយាមបង្ហាញចេញពីអារម្មណ៍ទាំងនេះតាមរយៈការគូររូប។ មិនមានបញ្ញត្តិណាមួយដែលកំណត់ថាកុមារត្រូវតែគូរគំនូរតាមរបៀបជាក់លាក់ណាមួយនោះ ដូច្នេះ យើងអាចរៀបចំទីកន្លែង និងសម្ភារៈៈសម្រាប់ឱ្យកុមារចូលរួមគូរបានដោយសេរី។

| | |
|---|---|
| មុខវិជ្ជា | - វិទ្យាសាស្ត្រ(គំនូរ) |
| វត្ថុបំណង | វិជ្ជាសម្បទា៖<br>- ប្រាប់បានពីឈ្មោះនៃរូបភាពដែលបានគូររួច<br>- ប្រាប់បានអំពីពណ៌ផ្សេងៗ។<br>បំណិនសម្បទា៖<br>- បញ្ជាក់របៀបគូរ និងការផាត់ពណ៌<br>- គូររូបភាព ឬផាត់ពណ៌បានត្រឹមត្រូវ<br>- កាន់ជក់ ឬខ្មៅដៃពណ៌ និងប្រើប្រាស់ទឹកពណ៌សម្រាប់គូរគំនូរ ផាត់ពណ៌បានត្រឹមត្រូវ។<br>ចរិយាសម្បទា៖<br>- រីករាយ និងសហការគ្នាបានល្អ<br>- ពេញចិត្តនឹងស្នាដៃរបស់ខ្លួន<br>- អភិវឌ្ឍន៍អារម្មណ៍ផ្សេងៗ។ |
| ថ្នាក់/អាយុ | - កម្រិតមធ្យម៤ឆ្នាំ |
| រយៈពេល | - ៣០នាទី(១ម៉ោងសិក្សា) |
| សម្ភារៈ | - ទឹកពណ៌ ជក់អេប៉ុងសម្រាប់បោះត្រា (យកអេប៉ុងកាត់តូចៗចងភ្ជាប់ជាមួយមែកឈើតូច ឬចង្កឹះ) ឬជក់សម្រាប់គូរ ឬផាត់ពណ៌ ក្រដាស ទឹកពណ៌ ចានលាយពណ៌ កែវទឹកដើម្បីលាងជក់ កូនកន្សែងសើម៖<br>• ក្រដាសដែលប្រើរួចម្ខាងសម្រាប់កុមារគូរសេរី ឬរៀបចំរូបភាពដែលមានស្រាប់សម្រាប់ផាត់ពណ៌ដូចជា រូបសត្វ បន្លែ ផ្លែឈើ អាហារ...<br>• ឧបករណ៍គូរគំនូរផ្សេងទៀតដូចជាខ្មៅដៃពណ៌ គូល័រទៀន អាចជំនួសដោយទឹកពណ៌បាន។ |
| របៀបលេង | - ឱ្យកុមារគូរ ឬផាត់ពណ៌តាមការចូលចិត្ត |
| លក្ខខណ្ឌ | - គ្មាន |

## ១. ការរៀបចំបរិស្ថាន និងការចូលរួមរបស់គ្រូ

### បរិស្ថាន





- បែងចែកកុមារជាក្រុមតូចៗអង្គុយនៅជុំវិញតុ
- រៀបចំសម្ភារៈសម្រាប់ក្រុមនីមួយៗ ក្នុងកញ្ច្រែង ដើម្បីឱ្យកុមារចេះទុកដាក់សម្ភារៈមានសណ្ដាប់ធ្នាប់ល្អ។

### ការចូលរួមរបស់គ្រូ





- ពន្យល់ពីរបៀបប្រើសម្ភារៈ។ ( ឧទាហរណ៍៖ របៀបប្រើដក់បរិមាណពណ៌ទឹកបន្តិចបន្តួចជាមួយដក់ សូមប្រយ័ត្នកុំឱ្យកំពប់ពណ៌ទឹកជាដើម )។
- លើកទឹកចិត្ត ទុកឱកាសឱ្យកុមារគូរតាមចំណូលចិត្ត គំនិត និងភាពច្នៃប្រឌិតរបស់កុមារ។ ក្នុងការលាយពណ៌ មិនមានខុស ឬត្រូវនោះទេសម្រាប់កុមារ។
- សង្កេតមើលសកម្មភាពឆ្លើយតបរបស់កុមារ និងនិយាយអំពីអ្វីដែលពួកគេកំពុងធ្វើ
- បន្ទាប់ពីលេងដក់អេប៉ុងរួចហើយ ឱ្យកុមារ លាងសម្អាត និងទុកកន្លែងដើមវិញ
- លើកទឹកចិត្តកុមារឱ្យទុកដាក់សម្ភារៈប្រើប្រាស់ឱ្យបានត្រឹមត្រូវ។



## ២. សកម្មភាពឆ្លើយតបរបស់កុមារ និងលទ្ធផល



- កុមារចូលចិត្តគូរគំនូរដោយប្រើទឹកពណ៌។ ឃើញដូច្នេះ គ្រូបានរៀបចំសកម្មភាព សម្រាប់គូរគំនូរ និងផាត់ទឹកពណ៌។
- កុមារីម្នាក់បានបោះត្រារាងមូលជាច្រើននៅលើក្រដាសដោយ ប្រើដក់ អេប៉ុងដែលគ្រូបានរៀបចំ។ គ្រូបានសួរថាតើទាំងនេះជាអ្វី ហើយនាងបានឆ្លើយតបថា «ទាំងនេះគឺជាថ្មនៅក្នុងទឹកជ្រោះ។ ខ្ញុំលេងនៅទីនោះជាមួយគ្រួសាររបស់ខ្ញុំ» ។ កុមារាម្នាក់ទៀតបានប្រើទឹកពណ៌គូររូបហើយនិយាយទៅកាន់គ្រូថា «ខ្ញុំបានគូរឡាន ខ្ញុំចង់បើកឡាននេះ»។ កុមារម្នាក់ៗចូលចិត្តគំនូរតាមរយៈការច្នៃប្រឌិតរៀងខ្លួន។
- បន្ទាប់ពីធ្វើសកម្មភាពចប់ គ្រូបានដាក់តាំងស្នាដៃកុមារនៅជ្រុងសិល្បៈ ដើម្បីឱ្យកុមារ និងឪពុកម្ដាយពេញចិត្តចំពោះពួកគេ។ ពេលឃើញស្នាដៃរបស់ខ្លួនដាក់តាំង កុមារខ្លះនិយាយថា«លើកក្រោយខ្ញុំចង់ប្រើពណ៌ផ្សេង ហើយគូររូបមិត្តភក្តិខ្ញុំ»។
- តាមរយៈការអនុវត្តសកម្មភាពនេះគ្រូបានដឹងពីចំណុចមួយចំនួន។ កុមារខ្លះមិនទាន់ចេះប្រើទឹកពណ៌ទេ ដូច្នេះគ្រូគួរតែរៀបចំទឹកពណ៌បន្តិចបន្តួចនៅក្នុងចាននីមួយៗជាមុន ដើម្បីឱ្យកុមារអាចប្រើវាបានយ៉ាងងាយស្រួល។ ដូចគ្នានេះដែរ កុមារខ្លះបានប្រើពណ៌ទឹកពួកគេមានចិត្តរំភើប និងព្យាយាមប្រើប្រាស់ទឹកពណ៌យ៉ាងសប្បាយ។ អ្នកគ្រូគិតថាលើកក្រោយគួរលើកទឹកចិត្តឱ្យកុមារ និងមាតាបិតារៀបចំសម្លៀកបំពាក់ធម្មតាសម្រាប់សកម្មភាពបែបនេះ ដើម្បីឱ្យកុមារបានធ្វើសកម្មភាពបានពេញលេញដោយមិនសូវខ្លាចប្រឡាក់។



ពិតមែនហើយ! ខ្ញុំចូលចិត្តផាត់ពណ៌។



បន្ទាប់ពីសកម្មភាពគំនូរស្នាដៃរបស់កុមារទាំងអស់ត្រូវបានដាក់តាំងនៅជ្រុងសិល្បៈ។

## ៣.៤. ជ្រុងល្បែង







ជ្រុងល្បែង គឺជាកន្លែងទុកដាក់សម្ភារៈល្បែងសម្រាប់ឱ្យកុមារលេងមានដូចជាល្បែង សាងសង់ ឡុកឡាក់ ឡូតូ ដូមីណូ ផ្គុំរូប ល្បែងច្នៃប្រឌិត និងល្បែងចិត្តចលភាព (បាល់ កង ចង់ខ្សាច់ កន្ត្រក ខ្សែលោតអន្ទាក់...) សម្រាប់ឱ្យកុមារលេង ទៅតាមចំណង់ចំណូលចិត្តរបស់ពួកគេ និងទុកដាក់របស់ទាំងនេះឱ្យមានរបៀបរៀបរយមានសណ្ដាប់ធ្នាប់ល្អ និងធ្វើឱ្យកុមារចង់លេង។

### ៣.៤.១. លទ្ធផលរំពឹងទុកលើការអភិវឌ្ឍរបស់កុមារ

| | |
|---|---|
| វិជ្ជាសម្បទា | - ប្រាប់ឈ្មោះជ្រុងល្បែង និងប្រភេទសម្ភារៈមាននៅក្នុងជ្រុង<br>- ប្រាប់បានពីឈ្មោះល្បែង របៀបលេង របៀបរៀបចំទុកដាក់ទៅតាមទីកន្លែង។ |
| បំណិនសម្បទា | - បង្ហាញឈ្មោះ និងប្រភេទសម្ភារៈមាននៅក្នុងជ្រុង<br>- កំណត់ល្បែង របៀបលេង និងរៀបចំទុកដាក់ត្រូវតាមទីកន្លែង<br>- ជ្រើសរើសសម្ភារៈដែលគេចូលចិត្តបានដោយខ្លួនឯង ស្គាល់នូវអ្វីដែលពួកគេចូលចិត្ត និងអភិវឌ្ឍន៍ការយល់ដឹងដោយខ្លួនឯង។ |
| ចរិយាសម្បទា | - ស្រឡាញ់ ចូលចិត្ត ថែរក្សាសម្ភារៈទុកដាក់ទៅតាមទីកន្លែង និងមានសណ្ដាប់ធ្នាប់ល្អដោយខ្លួនឯង<br>- លេងដោយប្រុងប្រយ័ត្ន និងមានសុវត្ថិភាព<br>- ទំនាក់ទំនងល្អ សហការគ្នាដោយរីករាយ និងលេងល្បែងដោយមិនបង្កទំនាស់<br>- ចាប់អារម្មណ៍ទៅលើអក្សរដែលសរសេរឈ្មោះ និងស្លាកសញ្ញាដែលបានបិទសម្គាល់។ |



### ៣.៤.២. ការរៀបចំ

**ក. ការរៀបចំជ្រុងល្បែង៖**

- រៀបចំជ្រុងសម្ភារៈល្បែងដោយដាក់ធ្នើរ ទូ ឬកញ្ច្រែងនៅកន្លែងដាក់លាក់មួយ។
- ដាក់សម្ភារៈល្បែង ឱ្យសមស្របនឹងចំនួនកុមារ ធ្វើយ៉ាងណាឱ្យកុមារទាំងអស់អាចមានល្បែងលេងមួយលេងក្នុងពេលតែមួយ។
- ការជ្រើសរើសសម្ភារៈល្បែងអាចទិញពីផ្សារ ផលិតដោយគ្រូ និងកុមារជាពិសេសសម្ភារៈផលិតពីសំណល់អាចកែច្នៃបាន។

**ខ. ការប្រើប្រាស់៖** ការរៀបចំធ្នើរឱ្យសមស្របនឹងកម្ពស់កុមារ ដើម្បីងាយស្រួលក្នុងការយកលេង និងទុកដាក់នៅកន្លែងដើមវិញបន្ទាប់ពីលេងរួច។

- បែងចែកសម្ភារៈតាមប្រភេទ តាមក្រុម ហើយដាក់ក្នុងកញ្ច្រែង កន្ត្រក ឬប្រអប់ក្រដាសត្រឹមត្រូវ។ បិទស្លាកសញ្ញាសម្គាល់នៅលើកញ្ច្រែងនីមួយៗ តាមការច្នៃប្រឌិតរបស់គ្រូ។ គ្រូអាចយករូបពីកញ្ចប់សម្ភារៈល្បែង ឬប្រអប់ក្រដាសសម្ភារៈមកបិទលើកញ្ច្រែងដូចក្នុងរូបខាងស្ដាំក៏បានដែរ។
- សម្អាតធ្នើរ និងល្បែងជាប្រចាំ។
- ការរៀបចំសម្ភារៈផ្លាស់ប្ដូរតាមប្រភេទល្បែង។ ល្បែងខ្លះមានបំណែកតូចៗជាច្រើន ដូចជាល្បែងផ្គុំរូបជាដើម។ ដើម្បីកាត់បន្ថយការបាត់បង់បំណែកទាំងនេះ យើងរៀបចំប្រអប់ដាក់ដាច់ដោយឡែក និងបិទស្លាកសញ្ញាសម្ភារៈល្បែងទាំងនោះ។
- ណែនាំកុមារពីការប្រើប្រាស់ធ្នើរនេះជាប្រចាំ ដោយពន្យល់ពីមុខល្បែងនីមួយ របៀបលេង និងរបៀបទុកដាក់នៅពេលលេងរួច។
- ក្នុងករណីខ្លះ គ្រូរៀបចំជ្រុងនេះជាមួយកុមារដើម្បីបង្រៀនគាត់ពីរបៀបទុកដាក់សម្ភារៈ និងមានសណ្ដាប់ធ្នាប់។





## ឧទាហរណ៍

### ល្បែងចាប់គូ



| | |
|---|---|
| មុខវិជ្ជា | - បុរេគណិតៈ ល្បែង ចាប់គូពណ៌ និងរូបភាពដូចគ្នា |
| វត្ថុបំណង | វិជ្ជាសម្បទាៈ<br>- ប្រាប់បានពីរូបភាព ពណ៌ និងរបៀបលេង<br>- ប្រាប់ពីចំនួនគូៗនៃកំប៉ុងរូបភាព។<br>បំណិនសម្បទាៈ<br>- ពន្យល់បានពីន័យនៃគូរបស់រូបភាព និងរៀបរាប់ពីពណ៌<br>- មានសមត្ថភាពសមហេតុផល( ចាប់គូរូបភាព/វត្ថុដូចគ្នា ឬមានទំនាក់ទំនងគ្នា )។<br>ចរិយាសម្បទាៈ<br>- ចែករំលែករូបភាព សប្បាយរីករាយ និងចេះសហការគ្នាក្នុងការលេង<br>- មានភាពអត់ធ្មត់ក្នុងការលេង<br>- មានភាពរហ័សរហួនក្នុងការលេង។ |
| ថ្នាក់/អាយុ | - កម្រិតខ្ពស់៥ឆ្នាំ |
| រយៈពេល | - ៣០នាទី( ១ម៉ោងសិក្សា ) |
| សម្ភារៈ | - កែវជ័របិទរូបជាគូៗ<br>- តុសម្រាប់ក្រុមកុមារ |
| របៀបលេង | - ប្រាប់ឈ្មោះល្បែង<br>- បែងចែកកុមារជាក្រុមតូចៗក្នុងមួយក្រុមចាប់ពី២នាក់ឡើងទៅ<br>- រៀបកែវលើតុឱ្យកុមារសង្កេត មុនពេលលេង<br>- កុមារត្រូវយកកែវដែលមានរូបដូចគ្នាដាក់ត្រួតពីលើគ្នាឱ្យត្រូវគូ ហើយយកដាក់នៅខាងមុខរៀងៗខ្លួន<br>សម្គាល់៖ ល្បែងនេះអាចលេងជាលក្ខណៈបុគ្គល ឬក្រុម។ |
| លក្ខខណ្ឌ | - កុមារប្រមូលបានកែវដែលត្រូវគូៗរូបភាពដូចគ្នាច្រើនជាងគេជាអ្នកឈ្នះ។ |

## ១. ការរៀបចំបរិស្ថាន និងការចូលរួមរបស់គ្រូ

### បរិស្ថាន





- ចែកកុមារជាក្រុមតូចតាមចំនួនដាក់ស្តែង
- រៀបចំតុ ឬទីកន្លែងតាមចំនួនក្រុម
- រៀបចំសម្ភារៈល្បែងសម្រាប់ក្រុមនីមួយៗតិច ឬច្រើនគូតាមចំនួនកុមារ និងចំនួនគូនៃកែវដែលមានរូបភាព
- បន្ទាប់ពីលេងរួចកុមារបានរៀបចំដាក់ក្នុងកញ្ច្រែង និងជួយរៀបចំសម្ភារៈត្រូវកន្លែងដើមវិញ។

### ការចូលរួមរបស់គ្រូ





- ណែនាំពីរបៀបលេង
- សាកល្បង និងលេងជាមួយកុមារប្រកបដោយការសប្បាយរីករាយ
- ដើរមើលតាមក្រុម ដើម្បីឱ្យដឹងថាកុមារមានបញ្ហាអ្វីខ្លះពេលកំពុងលេង
- សម្របសម្រួល និងលើកសរសើរដល់កុមារ
- សង្កេតពីសកម្មភាពឆ្លើយតបរបស់កុមារ។

## ២. សកម្មភាពឆ្លើយតបរបស់កុមារ និងលទ្ធផល



នៅពេលលេងដំបូង កុមារមិនទាន់យល់ពីរបៀបលេងទេ ទោះបីជាបានលេងសាកល្បងម្តងរួចហើយក៏ដោយ។ កុមារខ្លះចេះតែប្រមូលមកដាក់ខាងមុខកន្លែងរបស់ខ្លួន ទាំងខុសគូក៏មាន ខណៈពេលដែលកុមារខ្លះហាក់ដូចមិនដឹងថាត្រូវធ្វើអ្វី។ កុមារខ្លះទៀតមិនសូវសប្បាយចិត្តទេដោយសារតែលេងមិនឈ្នះគេសោះ ដោយនិយាយថា«ដណ្តើមមិនឈ្នះគេសោះ»។ ឃើញស្ថានភាពបែបនេះ គ្រូជួយកុមារដែលលែងមិនឈ្នះគេនោះ។ គ្រូបានពន្យល់ពីរបៀបលេងម្តងទៀត និងលើកទឹកចិត្តឱ្យលេងបន្តទៀត។ បន្ទាប់ពីលេង២ទៅ៣ដង កុមារចាប់ផ្តើមយល់ពីរបៀបលេងបានកាន់តែច្បាស់។ កុមារខ្លះដែលលេងមុនដំបូងមានភាពយឺតយ៉ាវលើកនេះចាប់ផ្តើមលឿនជាងមុនបន្តិចម្តងៗ។

កុមារខ្លះមើលទៅហាក់ដូចជាមិនទាន់លេងអស់ចិត្ត ព្រោះមិនទាន់បានឈ្នះនៅឡើយ។ ឃើញប្រតិកម្មដូច្នេះ គ្រូបានប្រាប់កុមារថា«អ្នកគ្រូនឹងរៀបល្បែងនេះនៅជ្រុងល្បែងសម្រាប់ប្អូនៗដែលចង់លេងបន្តបាននៅពេលចេញលេង» ហើយក៏រៀបទុកនៅជ្រុងនោះ។ កុមារមួយចំនួនបានទៅលេងបន្តនៅជ្រុងនេះនៅពេលចេញលេង។

តាមរយៈការលេងល្បែងនេះ គ្រូសង្កេតឃើញថាកុមារបានរៀនសូត្រជាច្រើនដូចជា៖

- ស្គាល់ពីបញ្ញត្តិគូ ស្គាល់រូបរាង ពណ៌ និងចំនួន។
- កុមារកាន់តែមានភាពរហ័សរហួនបន្ទាប់ពីលេងបាន២ទៅ៣ដង។
- កុមារចេះចែករំលែក។ កុមារខ្លះចាប់បានរូបដូចគ្នា ក្នុងនោះមានម្នាក់សុខចិត្តប្រគល់កំប៉ុងរបស់ខ្លួនឱ្យមិត្តភក្តិម្នាក់ទៀត បើទោះបីដឹងថាធ្វើបែបនេះគេអាចនឹងចាញ់ក៏ដោយ។ កុមារខ្លះទៀតជួយមិត្តភក្តិរបស់គេស្វែងរកគូ។
- គ្រូទទួលបានបទពិសោធថា បើមានការលេងល្បែងនេះលើកក្រោយ គួរផលិតចំនួនកំប៉ុងឱ្យបានកាន់តែច្រើន។
- កុមារខ្លះបាននិយាយថា«ហេតុអ្វីបានជាក្រុមរបស់យើងសុទ្ធតែស្រី» ដូច្នេះ ត្រូវរៀបចំឱ្យមានតុល្យភាពយេនឌ័រនៅពេលក្រោយ។



កុមារចេះតែប្រមូលកែវដាក់មុខរៀងខ្លួនបើ ទោះបីជាខុសគូក៏ដោយ



គ្រូពន្យល់បន្ថែមដល់កុមារតាមក្រុមនីមួយៗ



កុមាររីករាយនៅពេលដែលលេងឈ្នះ




រៀបចំល្បែងនៅជ្រុងល្បែង ឱ្យកុមារបានលេង នៅពេលក្រោយ

## ៣.៨. ជ្រុងសិក្សា

ជ្រុងសិក្សាគឺជាជ្រុងដែលរៀបចំឡើងសម្រាប់ទុកដាក់សម្ភារៈបង្រៀន និងរៀនដូចជាសៀវភៅរឿងនិទាន សៀវភៅឬផ្ទាំងរូបភាពផ្សេងៗទាក់ទងនឹងការសិក្សារបស់កុមារ និងសម្ភារៈដែលរៀនរួចតាមមុខវិជ្ជា។ គ្រូត្រូវរៀបចំទុកដាក់របស់របរទាំងនេះឱ្យមានរបៀបរៀបរយ មានសណ្តាប់ធ្នាប់ ថែរក្សាអនាម័យឱ្យបានល្អតាមមុខវិជ្ជានីមួយៗ ដើម្បីទាក់ទាញចំណាប់អារម្មណ៍របស់កុមារឱ្យចង់លេងល្បែងទាំងនោះដោយពេញចិត្ត។

### ៣.៨.១. ធ្នើរ ឬកន្លែងដាក់សៀវភៅ



ធ្នើរ ឬកន្លែងដាក់សៀវភៅគឺជាកន្លែងរៀបដាក់តាំងសៀវភៅសម្រាប់កុមារយកមកអានបានតាមតម្រូវការ។ សៀវភៅរូបភាពបានជះឥទ្ធិពលជាច្រើនដល់កុមារ។ ទោះបីជាកុមារមិនចេះអានអក្សរក៏ដោយ កុមារអាចអានរូបភាព។ កុមារចងចាំសាច់រឿងដែលគ្រូបានអាន ឬនិទាន ហើយពួកគាត់ចង់ឃើញសៀវភៅនេះម្តងទៀត។ ចុងក្រោយ កុមារទទួលបាននូវសារអប់រំផ្សេងៗពីសៀវភៅរូបភាពកាន់តែចាប់អារម្មណ៍លើភាសា និងការសរសេរ អភិវឌ្ឍន៍ញាណ ការស្រមើស្រមៃ និងបំណិនគិត។ ដូច្នេះ ត្រូវបង្កលក្ខណៈងាយស្រួលដល់កុមារអាចយកសៀវភៅដែលពួកគាត់ចូលចិត្តមកអានបានគ្រប់ពេល។

#### ៣.៨.១.១. លទ្ធផលរំពឹងទុកការអភិវឌ្ឍរបស់កុមារតូច

| | |
|---|---|
| វិជ្ជាសម្បទា | - ប្រាប់ពីប្រភេទសៀវភៅ និងចំណងជើងសៀវភៅ<br>- ប្រាប់បានពីទីកន្លែងទុកដាក់សៀវភៅ និងរូបភាពដែលមានក្នុងសៀវភៅរឿង។ |
| បំណិនសម្បទា | - កំណត់ពីប្រភេទសៀវភៅ និងចំណងជើងសៀវភៅ<br>- អភិវឌ្ឍការផ្តោតអារម្មណ៍តាមរយៈការស្តាប់រឿង<br>- អភិវឌ្ឍញាណ ការស្រមើស្រមៃពេលស្តាប់សាច់រឿង និងពេលទទួលបានអារម្មណ៍ផ្សេងៗ។ |
| ចរិយាសម្បទា | - ស្រឡាញ់ ចូលចិត្ត ថែរក្សាសៀវភៅ និងទុកដាក់មានសណ្តាប់ធ្នាប់<br>- បណ្តុះឱ្យកុមារមានទម្លាប់អានសៀវភៅ<br>- ចែករំលែកអារម្មណ៍ផ្សេងៗជាមួយមិត្តភក្តិពេលស្តាប់រឿងនិទាន<br>- អភិវឌ្ឍពាក្យពេចន៍និយាយស្តីបានត្រឹមត្រូវ។ |

#### ៣.៨.១.២. ការរៀបចំ

**ក. ការរៀបចំ៖** រៀបចំកន្លែងដាក់សៀវភៅ ដោយមានធ្នើរ ទូ ឬកញ្ច្រែងនៅក្នុងថ្នាក់រៀន និងមានលក្ខណៈងាយស្រួលសម្រាប់គ្រូ និងកុមារប្រើប្រាស់ដូចខាងក្រោម៖

- ជ្រើសរើសប្រភេទធ្នើរ ទូ ឬកញ្ច្រែង ហោប៉ៅសៀវភៅ ទៅតាមលទ្ធភាពរបស់សាលារៀន តែសូមពិនិត្យថាតើវាមានសុវត្ថិភាព អាចដាក់តាំងសៀវភៅបាននឹងល្អ និងសមស្របនឹងកម្ពស់របស់កុមារតូច។
- ដាក់ធ្នើរ ទូ ឬកញ្ច្រែង ហោប៉ៅសៀវភៅ នៅទីតាំងដែលកុមារងាយយកសៀវភៅមកអាន។
- រៀបចំឱ្យមានកន្លែងសម្រាប់កុមាររីករាយអានសៀវភៅ ដោយដាក់កម្រាលកៅស៊ូ ឬការ៉ូ ដើម្បីបង្កើនផាសុកភាពសម្រាប់កុមារអាន ដើម្បីញែកកន្លែងឱ្យកុមារដឹងថាកន្លែងណាសម្រាប់អង្គុយអានសៀវភៅ។
- អាស្រ័យតាមប្រភេទធ្នើរ រៀបចំដាក់តាំងឱ្យឃើញក្របសៀវភៅដើម្បីបង្កើតភាពទាក់ទាញដល់កុមារ។
- បើសិនជាមានសៀវភៅច្រើន គួររៀបសៀវភៅតាមប្រភេទតាមជាន់ ដូចជាប្រភេទសៀវភៅរូបភាព សៀវភៅវិទ្យាសាស្ត្រ ឬសៀវភៅរឿងបរទេសជាដើម។
- ណែនាំកុមារជាប្រចាំពីរបៀបយកអាន និងដាក់សៀវភៅទៅកន្លែងដើមវិញ។
- រៀបចំឱ្យមានកន្លែងសម្រាប់ដាក់តាំងសៀវភៅមកដល់ថ្មី បើអាចធ្វើទៅបាន។

**ខ. បរិមាណសៀវភៅ៖** រៀបចំចំនួនសៀវភៅសមស្របនឹងចំនួនកុមារ ធ្វើយ៉ាងណាឱ្យកុមារម្នាក់មានសៀវភៅមួយក្បាលអានក្នុងពេលតែមួយទាំងអស់គ្នា។

**គ. ការថែទាំ និងជួសជុល**

- ថែទាំ សម្អាត និងរក្សាអនាម័យជាប្រចាំ។
- ជួសជុលសៀវភៅជាប្រចាំ។
- ណែនាំកុមារឱ្យរាយការណ៍ទៅគ្រូនៅពេលមានសៀវភៅខូចខាត ឬហែក។

## ឧទាហរណ៍

### ការអានសេរីបន្ទាប់ពីស្តាប់ការនិទានរឿង

ក្នុងម៉ោងភាសាខ្មែរ គ្រូមត្តេយ្យសិក្សាបាននិទានរឿង«ទន្សាយចង់ស៊ីចេក»។ គ្រូសង្កេតឃើញថាកុមារពេលនោះកំពុងតែមានការចាប់អារម្មណ៍ខ្លាំងនឹងសាច់រឿង ហើយចង់ស្វែងយល់បន្ថែម។ ដូច្នេះគ្រូរៀបចំបរិស្ថានដោយមានសៀវភៅរូបភាពជាច្រើនឱ្យកុមារអានយ៉ាងសប្បាយរីករាយ។



| | |
|---|---|
| មុខវិជ្ជា | - ភាសាខ្មែរ៖ អំណានសេរី |
| វត្ថុបំណង | វិជ្ជាសម្បទា៖<br>- ប្រាប់បានពីរបៀបបើកសៀវភៅអាន<br>- ប្រាប់បានពីរូបភាពនៅក្នុងសៀវភៅ<br>- ប្រាប់បានពីទិសអំណាន។<br>បំណិនសម្បទា៖<br>- បើកសៀវភៅបានត្រឹមត្រូវ និងតាមទិសអំណាន<br>- រៀបរាប់ពីសកម្មភាព តាមលំដាប់លំដោយក្នុងសាច់រឿង។<br>ចរិយាសម្បទា៖<br>- បណ្តុះបានទម្លាប់ក្នុងការអានសៀវភៅ<br>- បណ្តុះបានភាពស្និទ្ធស្នាល និងសប្បាយរីករាយ។ |
| ថ្នាក់/អាយុ | - កម្រិតមធ្យម ៤ឆ្នាំ |
| រយៈពេល | - ៣០នាទី |
| សម្ភារៈ | - សៀវភៅនិទានរឿង រៀបចំនៅជ្រុងសិក្សា(ធ្នើរដាក់សៀវភៅ)ជាពិសេសសៀវភៅរឿង «ទន្សាយចង់ស៊ីចេក» សម្រាប់ដាក់តាំង<br>- កម្រាលកៅស៊ូ ឬកន្ទេលសម្រាប់កុមារអង្គុយស្តាប់រឿងនិទាន។ |
| របៀបដំណើរការ | - ឱ្យកុមារអានសេរីក្នុងថ្នាក់រៀន។ |

## ១. ការរៀបចំបរិស្ថាន និងការចូលរួមរបស់គ្រូ

### បរិស្ថាន





- រៀបចំតុទៅម្ខាង ដើម្បីឱ្យកុមារស្តាប់រឿងនិទានបានងាយស្រួល
- រៀបចំកន្លែងឱ្យកុមារស្តាប់រឿងនិទាន(កម្រាលកៅស៊ូ ឬកន្ទេលដែលងាយស្រួលសម្រាប់កុមារអង្គុយស្តាប់ និងអានរឿងនិទាន)
- រៀបចំកន្លែងកុមារអានសៀវភៅនៅក្នុងថ្នាក់រៀន
- រៀបចំសៀវភៅក្នុងធ្នើរឱ្យបានស្អាត និងតាំងបង្ហាញសៀវភៅរឿង «ទន្សាយចង់ស៊ីចេក»
- រៀបចំដាក់តាំងសៀវភៅរឿង«ទន្សាយចង់ស៊ីចេក» មានដូចជា ចេកពិត ត្រកួនដែលជាចំណីរបស់ទន្សាយ រូបតុក្កតាសត្វទន្សាយ សៀវភៅរូបភាពផ្លែឈើ និងរូបសត្វនៅជ្រុងវិទ្យាសាស្ត្រ ដើម្បីបន្ថែមការស្រាវជ្រាវ ពេលចេញលេង។

### ការចូលរួមរបស់គ្រូ



- នៅពេលនិទានរឿងចប់ គ្រូដឹងថាកុមារពិតជាចង់ស្វែងយល់ពីសាច់រឿងបន្ថែម។ ដើម្បីទាញការចាប់អារម្មណ៍របស់កុមារ នៅចុងបញ្ចប់នៃសាច់រឿង គ្រូបានប្រាប់ពីការរៀបចំនៅធ្នើរសៀវភៅ និងជ្រុងវិទ្យាសាស្ត្រ។
- លើកទឹកចិត្តឱ្យកុមារអាន និងខ្ចីសៀវភៅយកទៅផ្ទះ ដើម្បីឱ្យមាតាបិតាអានឱ្យស្តាប់
- បានចូលរួមជាមួយសិស្ស និងណែនាំពីរបៀបបើកសៀវភៅ ព្រមទាំងប្រាប់ពី រូបភាពសត្វ វត្ថុផ្សេងៗដល់កុមារ។

## ២. សកម្មភាពឆ្លើយតបរបស់កុមារ និងលទ្ធផល



កុមារខ្លះបានទៅកន្លែងផ្នើរដាក់សៀវភៅ រួចទាញយកសៀវភៅរឿងដែលទើបបាននិទាន និងខ្លះទៀតរកសៀវភៅណាដែលគាត់ចូលចិត្ត ហើយអង្គុយអានរៀងៗខ្លួន ឬជាក្រុម។ កុមារមើលរូបបណ្តើរ និទានរឿងឡើងវិញបណ្តើរតាមសាច់រឿង និងរូបភាពដែលគ្រូបាននិទាន ក្នុងពេលនោះមានកុមារម្នាក់បានប្រាប់ទៅមិត្តភក្តិគាត់ថា «អូនចង់មើលសៀវភៅដែលមានសត្វ និងផ្កាច្រើន» បន្ទាប់មកក៏បានទៅរកសៀវភៅនោះយកមកមើលជាមួយគ្នាយ៉ាងសប្បាយរីករាយ ដោយសួរគ្នាទៅវិញទៅមកថា«នេះជាសត្វអ្វី នោះជាសត្វអ្វី»។

កុមារ«មង្គល»បានយកដៃរុញសន្លឹកសៀវភៅបើកម្តងមួយទំព័រៗ ពេលនោះមានកុមារម្នាក់ទៀតឃើញដូច្នេះបានប្រាប់ថា«កុំបើកអ៊ីចឹងត្រូវកាន់ចុងសន្លឹកបើកម្តងមួយទំព័រៗ» ហើយគាត់បានធ្វើតាម។

ចំណែកឯជ្រុងវិទ្យាសាស្ត្រវិញ កុមារបន្តការសង្កេតទៅលើរូបភាពដែលបានឃើញពេលគ្រូនិទាន។ កុមារខ្លះនិយាយឆ្លើយឆ្លងគ្នាថា«នេះជាទន្សាយអម្បាញ់មិញ» «ទន្សាយនេះល្បិចណាស់» ជាដើម។ កុមារខ្លះ សង្កេតមើលផ្លែចេក ហើយនិយាយថា«ទន្សាយចូលចិត្តស៊ីផ្លែចេក ខ្ញុំក៏ចូលចិត្តញ៉ាំផ្លែចេកដែរ» ពួកគេបានប្រាប់ទៅមិត្តផ្សេងទៀតពីត្រកួន និងសត្វទន្សាយដែលគ្រូបានដាក់តាំងនៅជ្រុងវិទ្យាសាស្ត្រផងដែរ។



តាមរយៈសកម្មភាពនេះ គ្រូសង្កេតឃើញថា កុមារចាប់អារម្មណ៍សៀវភៅកាន់តែច្រើន នៅពេលដែលគ្រូបានឱ្យកុមារអានដោយសេរី បន្ទាប់ពីនិទានរឿង។ លើសពីនេះទៅទៀត ការខ្ចីសៀវភៅយកទៅអាននៅផ្ទះ ក៏មានការកើនឡើងជាងសព្វដង។

បន្ទាប់ពីរៀបចំសកម្មភាពនេះរួចមក គ្រូបានរកឃើញថា គួរតែបង្ហាញកុមារពីរបៀបបើកសៀវភៅឱ្យបានត្រឹមត្រូវ ព្រោះកុមារខ្លះមិនទាន់ដឹងពីការប្រើប្រាស់សៀវភៅនៅឡើយ។



កុមារស្តាប់រឿងនិទាន«ទន្សាយចង់ស៊ីផ្លែចេក»។



កុមារស្វែងរកសៀវភៅអាននៅផ្នើរដាក់សៀវភៅបន្ទាប់ពីបានស្តាប់រឿងនិទាន



គ្រូចូលរួមអានសៀវភៅជាមួយកុមារ។



មាតាបិតាខ្ចីសៀវភៅទៅអាននៅផ្ទះ

## ៣.៨.២. ធ្នើរ ឬកន្លែងដាក់សម្ភារៈសិក្សា






ធ្នើរ ឬកន្លែងដាក់សម្ភារៈសិក្សាជាទីកន្លែងរក្សាទុកដាក់ឯកសាររដ្ឋបាល សម្ភារៈប្រើប្រាស់ និងសម្ភារៈឧបទេសសម្រាប់ដំណើរការរៀន និងបង្រៀនមុខវិជ្ជានីមួយៗ បានត្រៀមផ្គត់ផ្គង់បម្រុងជាស្រេចតាមស្ថានភាពមូលដ្ឋានជាអាទិ៍មាន៖ សៀវភៅ បញ្ជីរដ្ឋបាលថ្នាក់រៀន ក្រដាស ប៊ិក ខ្មៅដៃ បន្ទាត់ កាវ ស្កុតកំណាត់ កន្ត្រៃ កាំបិត ខ្សែ អំបោះ ម្ជុលដេរ តួអក្សរ ឬលេខមានស្នាមចុច ប័ណ្ណ ព្យញ្ជនៈ ស្រៈ លេខ ផ្ទាំងរូបភាព សម្ភារៈពញ្ញាក់អារម្មណ៍ ម៉ែត្រវាស់កម្ពស់ ជញ្ជីងថ្លឹងទម្ងន់។ល។ អាស្រ័យលើការរៀបចំរបស់គ្រូ សម្ភារៈនៅទីនេះក៏អាចរៀបចំនៅជ្រុងល្បែងបានដែរ។

### ៣.៨.២.១. ប្រសិទ្ធភាព

- សម្រួលដល់ការបង្រៀន និងរៀន។
- ងាយស្រួលយកសម្ភារៈមកប្រើប្រាស់ក្នុងកិច្ចការងាររដ្ឋបាល។
- គ្រប់គ្រងសម្ភារៈបានគង់វង្ស និងមានសណ្ដាប់ធ្នាប់ល្អ។

### ៣.៨.២.២. ការរៀបចំ

**ក. សម្រាប់គ្រូ៖**

- ការរៀបចំ
  - ជ្រើសរើសធ្នើរ ទូដែក ទូឈើ ទៅតាមលទ្ធភាពរបស់សាលា។ ជាការល្អ យើងអាចជ្រើសរើសទូមានសោរ ដើម្បីបង្ការកុំឱ្យកុមារយកសម្ភារៈក្នុងទូរបស់គ្រូលេង។
- ការប្រើប្រាស់
  - រៀបតាមប្រភេទឯកសារ តាមមុខវិជ្ជា ឬសម្ភារៈ ក្នុងកញ្ច្រែង ឬប្រអប់ ដោយមានបិទស្លាកសញ្ញាសម្គាល់។
  - ផ្លាស់ប្ដូរសម្ភារៈបង្រៀនក្នុងធ្នើរជារៀងរាល់ខែដើម្បីកាត់បន្ថយបរិមាណក្នុងធ្នើរ។



- ការថែទាំ
  - សម្អាតធ្នើរ ឬកន្លែងដាក់សម្ភារៈជាប្រចាំ។
  - ណែនាំកុមារកុំឱ្យយកសម្ភារៈរបស់គ្រូលេង។




**ខ.សម្រាប់កុមារ៖**

- ការរៀបចំ
  - រៀបធ្នើរ ឬតុសម្រាប់ដាក់តាំងសម្ភារៈដែលគ្រូបង្រៀនរួចទុកឱ្យកុមារលេងមានដូចជាល្បែងគូសតាមស្នាម ចុចៗ លេខ ព្យញ្ជនៈ ល្បែងគូសភ្ជាប់ចំនួនទៅនឹងលេខ...។
- ការប្រើប្រាស់
  - រៀបចំសម្ភារៈល្បែងសិក្សាតាមមុខវិជ្ជាដាក់តាំងឱ្យកុមារងាយមើលឃើញ និងងាយយកលេង។
  - ផ្លាស់ប្ដូរល្បែងជាប្រចាំដែលមានបន្ថែមហ្វឹត និងអេប៉ុងលុបសម្រាប់កុមារលេង។



- ការថែទាំ
  - សម្អាតធ្នើរ ឬកន្លែងដាក់សម្ភារៈល្បែងជាប្រចាំ។
  - ណែនាំកុមារជាប្រចាំពីការរៀបចំទុកដាក់សម្ភារៈល្បែងនៅកន្លែងដើមវិញពេលលេងរួច។




ល្បែងសិក្សាតាមមុខវិជ្ជាក៏អាចដាក់នៅជ្រុងល្បែងឱ្យកុមារលេងបានដែរ។

## ឧទាហរណ៍

### ល្បែងផ្គុំចំនួនរូបភាពទៅនឹងលេខពី១ ដល់១០



មុននឹងលេងល្បែងផ្គុំរូប កុមារបានរៀនពីចំនួន រាប់ចំនួន និងយល់ន័យនៃ ចំនួន១ ដល់១០ រួចហើយ ដោយគ្រូបានបង្ហាញពីចំនួនរូបភាពឱ្យត្រូវនឹងចំនួនលេខ ព្រមទាំងរូបផ្សេងៗ សម្រាប់ឱ្យកុមារមានការចងចាំពីលេខទាំងនោះបានល្អជាងមុន។ ផ្សារភ្ជាប់នឹងសកម្មភាពនេះ គ្រូបានរៀបចំល្បែងមួយដែលហៅថា «ផ្គុំចំនួនរូបភាពទៅនឹងលេខ១ ដល់១០» ធ្វើបែបនេះ កុមារនឹងបានពង្រីកការយល់ដឹង ក៏ដូចជាបង្កើនការចងចាំពីចំនួនរូបភាព និងស្គាល់លេខនីមួយៗកាន់តែច្បាស់បន្ថែមទៀត ហើយនៅក្នុងល្បែងនេះ គ្រូបានរៀបចំបរិស្ថានសម្រាប់កុមារលេងផងដែរ។

| | |
|---|---|
| មុខវិជ្ជា | - បុរេគណិត ល្បែងផ្គុំចំនួនរូបភាពទៅនឹងលេខពី១ដល់១០ |
| វត្ថុបំណង | វិជ្ជាសម្បទា៖<br>- ប្រាប់បានពីពណ៌ ឈ្មោះរូបភាព ចំនួន និងលេខពី១ ដល់១០<br>បំណិនសម្បទា៖<br>- រាប់ចំនួនរូបភាព និងលេខបានពី១ ដល់១០<br>- ផ្គុំចំនួន និងលេខបានត្រឹមត្រូវ។<br>ចរិយាសម្បទា៖<br>- សប្បាយរីករាយ និងសហការគ្នាក្នុងពេលលេងបានល្អ។ |
| ថ្នាក់/អាយុ | - កម្រិតមធ្យម ៤ឆ្នាំ |
| រយៈពេល | - ៣០នាទី |
| សម្ភារៈ | - ល្បែងផ្ទាំងរូបភាព( ៤ឈុត ) |
| របៀបលេង | - កុមារផ្គុំចំនួនរូបភាពឱ្យត្រូវនឹងលេខ |



១. ការរៀបចំបរិស្ថាន និងការចូលរួមរបស់គ្រូ

#### បរិស្ថាន





- ដាក់សម្ភារៈនៅក្នុងប្រអប់ ហើយបិទស្លាកសញ្ញាសម្គាល់ទុកលើធ្នើរសម្ភារៈសិក្សា ឬតុ ងាយស្រួលកុមារមើលឃើញ និងយកលេង
- បែងចែកកុមារជាក្រុមតូចៗ
- រៀបតុផ្គុំបញ្ចូលគ្នា និងដាក់តាមចំនួនក្រុមកុមារ
- រៀបចំប្រអប់សម្ភារៈល្បែងដាក់លើតុឱ្យហើយ ងាយស្រួលដល់កុមារលេង។

#### ការចូលរួមរបស់គ្រូ



- បង្រៀនពីចំនួន និងលេខដល់កុមារ មុនពេលចាប់ផ្តើមលេងល្បែង
- ណែនាំពីរបៀបលេងទៅកាន់កុមារ
- ដើរមើលការលេងរបស់កុមារតាមក្រុម ដើម្បីឱ្យដឹងថាកុមារមានបញ្ហាអ្វីខ្លះពេលកំពុងលេង
- សម្របសម្រួល និងលើកសរសើរដល់កុមារ
- ចូលរួមលេងជាមួយកុមារប្រកបដោយភាពសប្បាយរីករាយ
- នៅចុងម៉ោងមុនពេលចេញលេង ណែនាំកុមារថា«អ្នកគ្រូបានរៀបល្បែងផ្គុំរូបភាពនៅធ្នើរសម្ភារៈសិក្សា និងតុ ហើយបើកូនណាចង់លេង អាចលេងដោយសេរីបាន»។

## ២. សកម្មភាពឆ្លើយតបរបស់កុមារ និងលទ្ធផល



កុមារពិតជាសប្បាយរីករាយនៅពេលឃើញគ្រូបានរៀបចំសម្ភារៈលេងនៅលើតុរបស់ពួកគេ បន្ទាប់មកគ្រូចាប់ផ្តើមឱ្យកុមារលេង។ តាមរយៈការលេងនេះ គ្រូបានសង្កេតឃើញថា មានកុមារមួយចំនួនតូចហាក់បីដូចជាមិនសូវជាចាប់អារម្មណ៍នឹងការលេងទេ ហើយព្រមទាំងមានកុមារខ្លះទៀតលេងមិនត្រូវសោះ បើទោះបីជាលេងបាន២ទៅ៣ដងក៏ដោយ។ ពេលនោះ គ្រូបានព្យាយាមណែនាំពីរបៀបលេង និងលើកទឹកចិត្តដល់កុមារដែលមិនសូវចង់លេង ចុងក្រោយពួកគេក៏បានលេងដោយជោគជ័យទាំងអស់គ្នា និងបានទះដៃស្រែកថា«ជយោ! យើងធ្វើបានហើយ»។

បន្ទាប់ពីលេងចប់ គ្រូបានរៀបចំសម្ភារៈទាំងនោះនៅជ្រុងសិក្សា ហើយបានណែនាំពួកគេឱ្យលេងនៅម៉ោងចេញលេង។ ក្នុងអំឡុងពេលនោះដែរ មានកុមារប្រមាណ៣ទៅ៤នាក់បានយកទៅលេងល្បែងនៅធ្នើរសម្ភារៈសិក្សា។ ក្រោយមកមានកុមារជាច្រើននាក់ទៀតចង់លេងដែរ តែគ្រូបានណែនាំឱ្យកុមារចាំលេងនៅពេលក្រោយទៀត ដោយសារកន្លែងចង្អៀត។



នៅក្នុងសកម្មភាពនេះ យើងឃើញថាមានចំណុចមួយចំនួនគ្រូគួរតែកែលម្អនៅពេលក្រោយ៖

- គ្រូគួររៀបចំបណ្ណរូបភាព និងបណ្ណលេខឱ្យបានទំហំធំជាងនេះ ដើម្បីឱ្យកុមារយល់ និងមើលឃើញបានច្បាស់។
- គ្រូគួររៀបចំឱ្យកុមារលេងល្បែងនៅពាក់កណ្តាលម៉ោងសិក្សា (ឧ៖ នៅម៉ោង៨:៣០ព្រឹក ឬម៉ោង៩:០០ព្រឹក) ចៀសវាងកុមារមានភាពនឿយហត់ពេលលេងល្បែងនេះ
- គ្រូគួរលើកទឹកចិត្តកុមារឱ្យបានច្រើន បើទោះបីជាគាត់លេងខុសដដែលៗក៏ដោយ។



គ្រូពន្យល់បន្ថែមដល់កុមារ



កុមារជួយគ្នាស្វែងរកគូរូបភាព និងចំនួន



កុមារលេងល្បែងនៅពេលសម្រាក